**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ ៤៥៦ ស.ខ.ល

# សេចក្តីសម្រេច

## ស្តីពី

## នីតិវិធីប្រតិបត្តិស្តង់ដាស្តីពីការធ្វើចត្តាឡីស័ករបស់អ្នកដំណើរមកពីបរទេស ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋាន បានពេញលេញ

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/004 ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

- បានឃើញអនុក្រឹត្យលេខ៨៥ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២១ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩

## សម្រេច

**ប្រការ១ .-**

ត្រូវបានដាក់ឱ្យប្រើនីតិវិធីប្រតិបត្តិស្តង់ដាស្ដីពីការធ្វើចត្តាឡីស័ករបស់អ្នកដំណើរមកពីបរទេសដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋាន បានពេញលេញ ដែលជាឧបសម្ព័ន្ធនៃសេចក្ដីសម្រេចនេះ។

**ប្រការ២ .-**

ការដាក់ឱ្យប្រើនីតិវិធីប្រតិបត្តិស្តង់ដាស្ដីពីការធ្វើចត្តាឡីស័ករបស់អ្នកដំណើរមកពីបរទេសដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋាន បានពេញលេញ មានវិសាលភាពអនុវត្តទូទាំងប្រទេស។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

ខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គាធិការដ្ឋានក្រសួងសុខាភិបាល គណៈប្រតិបត្តិនៃគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ អនុគណៈកម្មការនានាចំណុះឱ្យគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ លេខាធិការដ្ឋានរបស់គណៈប្រតិបត្តិនៃគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ រាជធានី-ខេត្ត និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសុខាភិបាល ត្រូវអនុវត្តតាមសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១៤កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០២១

**ម៉ម ប៊ុនហេង**

**កន្លែងទទួល :**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គណៈប្រចាំការនៃ **គ.ម.ក.**
- ដូចប្រការ៤
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# នីតិវិធីប្រតិបត្តិស្តង់ដាស្តីពីការធ្វើចត្តាឡីស័ករបស់អ្នកដំណើរមកពីបរទេសដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋាន បានពេញលេញ

ខែតុលា ឆ្នាំ២០២១

# មាតិកា


**អារម្ភកថា**

**សេចក្តីផ្តើម**

**ក. អ្នកដំណើរដែលបានចាក់វ៉ាក់សាំង ដូសមូលដ្ឋាន បានពេញលេញ.............................. ១**

១-គៀវផ្លូវការរបស់រាជរដ្ឋាភិបាល និងមន្ត្រីថ្នាក់ដឹកនាំជាន់ខ្ពស់របស់រាជរដ្ឋាភិបាលដែលត្រឡប់ពីបំពេញបេសកកម្មនៅក្រៅប្រទេស .............................. ១

២-អ្នកដំណើរជាមន្ត្រីរាជការដែលត្រឡប់ពីបំពេញបេសកកម្មផ្លូវការនៅក្រៅប្រទេសនិងក្រុមគ្រួសារ.......... ១

២.១- លក្ខខណ្ឌធ្វើដំណើរ .............................. ១

២.២- ការអនុវត្តវិធានការសុខាភិបាលនិងការធ្វើចត្តាឡីស័ក..............................២

៣-មន្ត្រីការទូតបរទេស និងមន្ត្រីអនុវត្តគម្រោងសហប្រតិបត្តិការផ្លូវការ និងក្រុមគ្រួសារ..............................៣

៣.១- លក្ខខណ្ឌធ្វើដំណើរ.............................. ៣

៣.២- ការអនុវត្តវិធានការសុខាភិបាលនិងការធ្វើចត្តាឡីស័ក.............................. ៣

៤-អ្នកដំណើរបរទេសដែលជាវិនិយោគិន បុគ្គលិកជំនាញបច្ចេកទេស បុគ្គលិកក្រុមហ៊ុន និងក្រុមគ្រួសារ ដែលមានការធានា ឬការអញ្ជើញ.............................. ៤

៤.១- លក្ខខណ្ឌធ្វើដំណើរ.............................. ៥

៤.២- ការអនុវត្តវិធានការសុខាភិបាលនិងការធ្វើចត្តាឡីស័ក.............................. ៦

៥-អ្នកដំណើរទូទៅជាជនជាតិខ្មែរ ឬជនបរទេស.............................. ៦

៥.១- សម្រាប់ជនជាតិខ្មែរ .............................. ៦

៥.១.១- លក្ខខណ្ឌធ្វើដំណើរ .............................. ៧

៥.១.២- ការអនុវត្តវិធានការសុខាភិបាលនិងការធ្វើចត្តាឡីស័ក .............................. ៧

៥.២- អ្នកដំណើរទូទៅជាជនបរទេស .............................. ៨

៥.២.១- លក្ខខណ្ឌធ្វើដំណើរ.............................. ៨

៥.២.២- ការអនុវត្តវិធានការសុខាភិបាលនិងការធ្វើចត្តាឡីស័ក.............................. ៩

**ខ. អ្នកដំណើរគ្រប់ប្រភេទដែលមិនបានចាក់វ៉ាក់សាំងកូវីដ-១៩ ឬមិនទាន់ចាក់វ៉ាក់សាំង ដូសមូលដ្ឋានបានពេញលេញ.............................. ១០**

**តារាងសង្ខេបស្តីពីការធ្វើចត្តាឡីស័កសម្រាប់អ្នកដំណើរមកកម្ពុជាតាមច្រកចូល .............................. ១១**

**ឧបសម្ព័ន្ធទី១ .............................. ១២**

**ឧបសម្ព័ន្ធទី២.............................. ១៣**

**ឧបសម្ព័ន្ធទី៣.............................. ១៤**


ខ

# អារម្ភកថា

តាមរយៈការដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលដែលមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាប្រមុខ ការដាក់ចេញនូវវិធានការនិងការបង្កើតនូវយន្តការនានា ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព គួបផ្សំនឹងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ជាន់ថ្នាក់ រួមទាំងការចូលរួមយ៉ាងសស្រាក់សស្រាំពីអ្នកពាក់ព័ន្ធគ្រប់មជ្ឈដ្ឋាន ទាំងបណ្តាដៃគូអភិវឌ្ឍ សប្បុរសជន និងប្រជាពលរដ្ឋ បានជួយជំរុញឱ្យយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សំដៅបង្កើតភាពស៊ាំសហគមន៍នៅទូទាំងព្រះរាជាណាចក្រកម្ពុជាអាចដំណើរការបានដោយរលូន ដែលអាចឱ្យកម្ពុជាគ្រប់គ្រងសភាពការណ៍បាន។ ដោយអត្រានៃការចាក់វ៉ាក់សាំងជិតសម្រេចបានតាមគោលដៅដែលបានគ្រោងទុក គួបផ្សំនឹងយុទ្ធនាការចាក់ដូសជំរុញបន្ថែមទៀត និងដោយមើលឃើញពីការវិវត្តកាន់តែប្រសើរឡើងនៃស្ថានភាពជាក់ស្តែង រាជរដ្ឋាភិបាលបានសម្រេចបើកសាលារៀនឡើងវិញ ហើយបានបើកដំណើរការសកម្មភាពសង្គម-សេដ្ឋកិច្ចឡើងវិញជាជំហានៗ តាមគន្លងប្រក្រតីភាពថ្មី បង្កើតនូវកាលានុវត្តភាពទាក់ទាញអ្នកវិនិយោគជាតិនិងអន្តរជាតិ និងដៃគូអភិវឌ្ឍ ដោយបន្តប្រកាន់ខ្ជាប់នូវភាពប្រុងប្រយ័ត្នខ្ពស់ជានិច្ច។

នីតិវិធីប្រតិបត្តិស្តង់ដាស្តីពីការធ្វើចត្តាឡីស័ករបស់អ្នកដំណើរមកពីបរទេសដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋាន បានពេញលេញ ត្រូវបានរួមគ្នាតាក់តែងឡើងដោយក្រុមការងារចំណុះអនុគណៈកម្មការគ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេស ដោយសហការជាមួយអនុគណៈកម្មការនានាចំណុះគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដោយផ្អែកលើការចង្អុលបង្ហាញទិសរបស់គណៈប្រចាំការគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ តាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់បំផុតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** តាមរយៈការពិនិត្យ វាយតម្លៃលើការសាកល្បងយ៉ាងល្អិតល្អន់និងគ្រប់ជ្រុងជ្រោយគ្រប់ទិដ្ឋភាពហានិភ័យដែលបានកើតមាននិងអាចកើតមាន នាពេលខាងមុខ។

ក្នុងនាមក្រសួងសុខាភិបាលនិងគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ ខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្តមប្រធានអនុគណៈកម្មការគ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័កនិងក្រុមការងារពាក់ព័ន្ធផ្សេងៗដែលខិតខំរៀបចំនីតិវិធីប្រតិបត្តិស្តង់ដាដ៏មានសារៈសំខាន់នេះឡើង។ ខ្ញុំជឿជាក់ថា នីតិវិធីប្រតិបត្តិស្តង់ដាស្តីពីការធ្វើចត្តាឡីស័ករបស់អ្នកដំណើរមកពីបរទេសដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋាន បានពេញលេញ នឹងក្លាយជាលិខិតបទដ្ឋានមួយ សម្រាប់អនុវត្តនៅទូទាំងប្រទេស ដើម្បីធានាបាននូវការបើកដំណើរការសកម្មភាពសង្គម-សេដ្ឋកិច្ចឡើងវិញជាជំហានៗ តាមគន្លងប្រក្រតីភាពថ្មី ប្រកបដោយប្រសិទ្ធភាព និងរួមគ្នាកាត់បន្ថយជាអតិបរមានូវលទ្ធភាពចម្លងរោគនិងការរីករាលដាលនៃជំងឺកូវីដ-១៩ តាមរយៈអ្នកដំណើរមកពីបរទេសចូលមកកម្ពុជា។

ថ្ងៃ ពុធ ១៤កើត ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងសុខាភិបាលនិងជាប្រធានគណៈកម្មការ**

**អន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩**

**ម៉ម ប៊ុនហេង**

# សេចក្តីផ្តើម

នីតិវិធីប្រតិបត្តិស្តង់ដាស្តីពីការធ្វើចត្តាឡីស័ករបស់អ្នកដំណើរមកពីបរទេសដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋាន បានពេញលេញ ត្រូវបានរៀបចំឡើងក្នុងគោលបំណងធានាសុវត្ថិភាពសុខភាពសាធារណៈតាមរយៈការពង្រឹងការអនុវត្តវិធានការសុខាភិបាលឱ្យកាន់តែមានប្រសិទ្ធភាព ក៏ដូចជាដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកដំណើរដែលបានចាក់វ៉ាក់សាំងពេញលេញ ព្រមទាំងបង្កើតនូវកាលានុវត្តភាពទាក់ទាញអ្នកវិនិយោគជាតិនិងអន្តរជាតិ និងដៃគូអភិវឌ្ឍ ដោយបន្តប្រកាន់ខ្ជាប់នូវភាពប្រុងប្រយ័ត្នខ្ពស់ជានិច្ច។ នីតិវិធីប្រតិបត្តិស្តង់ដានេះក៏កំណត់អំពីគោលការណ៍សម្រាប់អ្នកដំណើរដែលមិនទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ ឬចាក់វ៉ាក់សាំងមិនទាន់បានពេញលេញ ផងដែរ។

នីតិវិធីប្រតិបត្តិស្តង់ដានេះ**កំណត់លក្ខខណ្ឌធ្វើដំណើរ និងការអនុវត្តវិធានការសុខាភិបាលនិងការធ្វើចត្តាឡីស័កនៅកម្ពុជា**សម្រាប់អ្នកដំណើរចូលមកកម្ពុជា ស្របតាមគន្លងប្រក្រតីភាពថ្មី ចំពោះអ្នកដំណើរ រួមមាន **(១)** ភ្ញៀវផ្លូវការរបស់រាជរដ្ឋាភិបាល និងមន្ត្រីថ្នាក់ដឹកនាំជាន់ខ្ពស់របស់រាជរដ្ឋាភិបាលដែលត្រឡប់ពីបំពេញបេសកកម្មនៅក្រៅប្រទេស **(២)** អ្នកដំណើរជាមន្ត្រីរាជការ ដែលត្រឡប់ពីបំពេញបេសកកម្មផ្លូវការនៅក្រៅប្រទេស និងក្រុមគ្រួសារ **(៣)** មន្ត្រីការទូតបរទេស និងមន្ត្រីអនុវត្តគម្រោងសហប្រតិបត្តិការផ្លូវការ និងក្រុមគ្រួសារ **(៤)** អ្នកដំណើរបរទេសដែលជាវិនិយោគិន បុគ្គលិកជំនាញបច្ចេកទេស បុគ្គលិកក្រុមហ៊ុន និងក្រុមគ្រួសារ ដែលមានការធានា ឬការអញ្ជើញ **(៥)** អ្នកដំណើរទូទៅជាជនជាតិខ្មែរ ឬជនបរទេស និង **(៦)** អ្នកដំណើរគ្រប់ប្រភេទដែលមិនបានចាក់វ៉ាក់សាំងកូវីដ-១៩ ឬមិនទាន់ចាក់វ៉ាក់សាំង ដូសមូលដ្ឋាន បានពេញលេញ។

ខ្លឹមសារនៃនីតិវិធីប្រតិបត្តិស្តង់ដានេះត្រូវបានបែងចែកទៅតាមប្រភេទអ្នកដំណើរពីបរទេសចូលមកកម្ពុជាតាមច្រកទ្វារចេញ-ចូលប្រទេស ដែលមានកំណត់លម្អិតអំពីលក្ខខណ្ឌធ្វើដំណើរ ការអនុវត្តវិធានការសុខាភិបាល និងការធ្វើចត្តាឡីស័កនៅកម្ពុជា ដើម្បីផ្តល់ព័ត៌មានងាយស្រួលដល់អ្នកដែលមានបំណងធ្វើដំណើរចូលមកកម្ពុជា និងដល់អាជ្ញាធរកម្ពុជាអនុវត្ត។

នីតិវិធីប្រតិបត្តិស្តង់ដានេះត្រូវបានចាត់ទុកជាលិខិតបទដ្ឋានគតិយុត្តមួយសម្រាប់តម្រង់ទិសដល់អាជ្ញាធរកម្ពុជាដែលពាក់ព័ន្ធដើម្បីយកទៅអនុវត្ត ប្រកបដោយប្រសិទ្ធភាព មនសិការវិជ្ជាជីវៈ ទំនួលខុសត្រូវខ្ពស់លើតួនាទីនិងភារកិច្ចខ្លួន ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ដើម្បីធានាសុវត្ថិភាពសុខភាពសាធារណៈ តាមរយៈការពង្រឹងការអនុវត្តវិធានការសុខាភិបាលឱ្យកាន់តែមានប្រសិទ្ធភាព ក៏ដូចជាដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកដំណើរចូលមកកម្ពុជា គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ សម្រេចកំណត់លក្ខខណ្ឌធ្វើដំណើរ ការអនុវត្តវិធានការសុខាភិបាល និងការធ្វើចត្តាឡីស័កស្របតាមគន្លងប្រក្រតីភាពថ្មី ដូចតទៅ÷

**ក. អ្នកដំណើរដែលបានចាក់វ៉ាក់សាំង ដូសមូលដ្ឋាន បានពេញលេញ**

- ភ្ញៀវផ្លូវការរបស់រាជរដ្ឋាភិបាល និងមន្ត្រីថ្នាក់ដឹកនាំជាន់ខ្ពស់របស់រាជរដ្ឋាភិបាលដែលត្រឡប់ពីបំពេញបេសកកម្មនៅក្រៅប្រទេស (រយៈពេលចត្តាឡីស័កតាមការសម្រេចរបស់រាជរដ្ឋាភិបាល)
- អ្នកដំណើរជាមន្ត្រីរាជការ ដែលត្រឡប់ពីបំពេញបេសកកម្មផ្លូវការនៅក្រៅប្រទេស និងក្រុមគ្រួសារ (រយៈពេលចត្តាឡីស័ក **ចំនួន៣ថ្ងៃ**)
- មន្ត្រីការទូតបរទេស និងមន្ត្រីអនុវត្តគម្រោងសហប្រតិបត្តិការផ្លូវការ និងក្រុមគ្រួសារ (រយៈពេលចត្តាឡីស័ក **ចំនួន៣ថ្ងៃ**)
- អ្នកដំណើរបរទេសដែលជាវិនិយោគិន បុគ្គលិកជំនាញបច្ចេកទេស បុគ្គលិកក្រុមហ៊ុន និងក្រុមគ្រួសារដែលមានការធានា ឬការអញ្ជើញ (រយៈពេលចត្តាឡីស័ក **ចំនួន៣ថ្ងៃ**)
- អ្នកដំណើរទូទៅជាជនជាតិខ្មែរ ឬជនបរទេស (រយៈពេលចត្តាឡីស័ក **ចំនួន ៧ថ្ងៃ**)

**ខ. អ្នកដំណើរគ្រប់ប្រភេទ ដែលមិនបានចាក់វ៉ាក់សាំងកូវីដ-១៩ ឬមិនទាន់ចាក់វ៉ាក់សាំង ដូសមូលដ្ឋាន បានពេញលេញ (រយៈពេល ១៤ថ្ងៃ)។**

## ក. អ្នកដំណើរដែលបានចាក់វ៉ាក់សាំង ដូសមូលដ្ឋាន បានពេញលេញ

### ១-ភ្ញៀវផ្លូវការរបស់រាជរដ្ឋាភិបាល និងមន្ត្រីថ្នាក់ដឹកនាំជាន់ខ្ពស់របស់រាជរដ្ឋាភិបាលដែលត្រឡប់ពីបំពេញបេសកកម្មនៅក្រៅប្រទេស

លក្ខខណ្ឌធ្វើដំណើរ និងការអនុវត្តវិធានការសុខាភិបាលនិងការធ្វើចត្តាឡីស័កសម្រាប់ភ្ញៀវផ្លូវការរបស់រាជរដ្ឋាភិបាល និងមន្ត្រីថ្នាក់ដឹកនាំជាន់ខ្ពស់របស់រាជរដ្ឋាភិបាលដែលត្រឡប់ពីបំពេញបេសកកម្មនៅក្រៅប្រទេស ត្រូវកំណត់ដោយការសម្រេចរបស់រាជរដ្ឋាភិបាលដោយផ្អែកតាមករណីនីមួយៗ។

### ២-អ្នកដំណើរជាមន្ត្រីរាជការដែលត្រឡប់ពីបំពេញបេសកកម្មផ្លូវការនៅក្រៅប្រទេសនិងក្រុមគ្រួសារ

**២.១- លក្ខខណ្ឌធ្វើដំណើរ**

**មុនពេលធ្វើដំណើរមកដល់កម្ពុជា** អ្នកដំណើរត្រូវត្រៀមឱ្យរួចរាល់នូវឯកសារដូចខាងក្រោម÷

- លិខិតបេសកកម្មផ្លូវការចេញដោយក្រសួងឬស្ថាប័នសាមី
- វិញ្ញាបនបត្របញ្ជាក់ថាគ្មានជំងឺកូវីដ-១៩ ក្នុងរយៈពេល៧២ម៉ោងមុនពេលមកដល់កម្ពុជាទទួលស្គាល់ដោយអាជ្ញាធរសុខាភិបាលនៃប្រទេសដែលមន្ត្រីបំពេញបេសកកម្ម

- ត្រូវមានបណ្ណឬវិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩ ដែលបញ្ជាក់ពីការចាក់វ៉ាក់សាំង ដូសមូលដ្ឋានបានពេញលេញ ប្រភេទវ៉ាក់សាំងនិងកាលបរិច្ឆេទនៃការចាក់វ៉ាក់សាំង
- ឯកសារបញ្ជាក់ការកក់សណ្ឋាគារ ក្នុងករណីអ្នកដំណើរចង់ធ្វើចត្តាឡីស័កនៅសណ្ឋាគារ ដែលទទួលសេវាកក់តាមអនឡាញ ដូចមានបង្ហាញក្នុងឧបសម្ព័ន្ធទី១។

**ពេលមកដល់ច្រកទ្វារចេញ-ចូលប្រទេសកម្ពុជា** អ្នកដំណើរត្រូវបង្ហាញគ្រប់ឯកសារពាក់ព័ន្ធខាងលើ។

## ២.២-ការអនុវត្តវិធានការសុខាភិបាលនិងការធ្វើចត្តាឡីស័ក

បន្ទាប់ពីទទួលបានការត្រួតពិនិត្យឯកសារតម្រូវដូចខាងលើ អ្នកដំណើរនឹងត្រូវបានពិនិត្យសុខភាពនិងយកសំណាកដើម្បីធ្វើតេស្ត PCR ដោយមន្ត្រីសុខាភិបាល នៅទីតាំងច្រកចូលប្រទេសកម្ពុជា មុនទៅសណ្ឋាគារឬទីតាំងដែលកំណត់ដោយក្រសួងសុខាភិបាល ដើម្បីធ្វើចត្តាឡីស័ក។

ក្នុងករណីអ្នកដំណើរមានបំណងប្រើប្រាស់សេវាចត្តាឡីស័កនៅសណ្ឋាគារបង់ថ្លៃសេវាដោយខ្លួនឯង មន្ត្រីសម្របសម្រួលនៅច្រកទ្វារចេញ-ចូលប្រទេស នឹងរៀបចំឱ្យអ្នកដំណើរបានទៅធ្វើចត្តាឡីស័កនៅសណ្ឋាគារបន្ទាប់ពីបានយកសំណាករួចរាល់។

ក្នុងករណីអ្នកដំណើរសុខចិត្តស្នាក់នៅសណ្ឋាគារដែលកំណត់ដោយក្រសួងសុខាភិបាល ការចំណាយជាបន្ទុករបស់រដ្ឋ។

ក្រោយពេលទៅដល់ទីតាំងចត្តាឡីស័កនៅសណ្ឋាគារឬទីតាំងដែលកំណត់ដោយក្រសួងសុខាភិបាល អ្នកដំណើរនឹងត្រូវរង់ចាំលទ្ធផលតេស្តចំនួន **៣ថ្ងៃ**÷

- ក្នុងករណីលទ្ធផលតេស្ត PCR បញ្ជាក់ថា វិជ្ជមានកូវីដ-១៩ អ្នកដំណើរនឹងត្រូវបញ្ជូនទៅព្យាបាលនៅតាមទីតាំងព្យាបាលជំងឺកូវីដ-១៩ ដែលអនុញ្ញាតដោយក្រសួងសុខាភិបាល
- ក្នុងករណីលទ្ធផលតេស្ត PCR បញ្ជាក់ថា អវិជ្ជមានកូវីដ-១៩ អ្នកដំណើរនឹងត្រូវបញ្ចប់ការធ្វើចត្តាឡីស័ក នៅថ្ងៃទី៣។

ក្នុងករណីគេហដ្ឋានរបស់មន្ត្រីរាជការខាងលើមានភាពសមស្របដល់ការធ្វើចត្តាឡីស័កស្របតាមវិធានការចត្តាឡីស័កនៅផ្ទះ អ្នកដំណើរជាមន្ត្រីរាជការអាចស្នើសុំមកអនុគណៈកម្មការទី២ យ៉ាងតិច៣ថ្ងៃនៃថ្ងៃធ្វើការមុនពេលមកដល់កម្ពុជា ដើម្បីធ្វើចត្តាឡីស័កនៅផ្ទះ។ ក្រោយពីពិនិត្យលើការស្នើសុំ អនុគណៈកម្មការទី២ អាចបដិសេធឬឯកភាពអនុញ្ញាតដោយភ្ជាប់នូវលក្ខខណ្ឌនិងវិធានការសុខាភិបាលសម្រាប់អ្នកដំណើរអនុវត្តដោយការទទួលខុសត្រូវខ្ពស់ចំពោះមុខច្បាប់នៃព្រះរាជាណាចក្រកម្ពុជាជាធរមាន។

ក្នុងអំឡុងពេលធ្វើចត្តាឡីស័ក អ្នកដែលត្រូវធ្វើចត្តាឡីស័កត្រូវគោរពតាមនីតិវិធីសម្រាប់ការធ្វើចត្តាឡីស័កនៅតាមផ្ទះ (ករណីធ្វើចត្តាឡីស័ក នៅតាមផ្ទះ) និងនីតិវិធីប្រតិបត្តិស្តង់ដាសម្រាប់ការគ្រប់គ្រងអ្នកដំណើរនៅតាមសណ្ឋាគារចត្តាឡីស័ក (ករណីធ្វើចត្តាឡីស័កនៅសណ្ឋាគារ) ជាធរមាន។

## ៣-មន្ត្រីការទូតបរទេស និងមន្ត្រីអនុវត្តគម្រោងសហប្រតិបត្តិការផ្លូវការ និងក្រុមគ្រួសារ

លក្ខខណ្ឌធ្វើដំណើរ និងការអនុវត្តវិធានការសុខាភិបាលនិងការធ្វើចត្តាឡីស័កចំពោះមន្ត្រីការទូតបរទេស និងមន្ត្រីអនុវត្តគម្រោងសហប្រតិបត្តិការផ្លូវការដែលកាន់ទិដ្ឋាការការទូត (Visa A) និងទិដ្ឋាការផ្លូវការ (Visa B) និងក្រុមគ្រួសារ ត្រូវអនុវត្ត ដូចខាងក្រោម÷

### ៣.១- លក្ខខណ្ឌធ្វើដំណើរ

**មុនពេលធ្វើដំណើរមកដល់កម្ពុជា** អ្នកដំណើរត្រូវត្រៀមឱ្យរួចរាល់នូវឯកសារដូចខាងក្រោម÷

- វិញ្ញាបនបត្របញ្ជាក់ថាគ្មានជំងឺកូវីដ-១៩ ក្នុងរយៈពេល៧២ម៉ោងមុនពេលមកដល់កម្ពុជា ទទួលស្គាល់ដោយអាជ្ញាធរសុខាភិបាលនៃប្រទេសសាមីឬទីសំណាក់ចុងក្រោយមុនចាកចេញមកកាន់កម្ពុជា
- ត្រូវមានបណ្ណឬវិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩ ដែលបញ្ជាក់ពីការចាក់វ៉ាក់សាំង ដូសមូលដ្ឋានបានពេញលេញ ប្រភេទវ៉ាក់សាំងនិងកាលបរិច្ឆេទនៃការចាក់វ៉ាក់សាំង។

**ពេលមកដល់ច្រកទ្វារចេញ-ចូលប្រទេសកម្ពុជា** អ្នកដំណើរត្រូវបង្ហាញគ្រប់ឯកសារពាក់ព័ន្ធខាងលើ។

### ៣.២- ការអនុវត្តវិធានការសុខាភិបាលនិងការធ្វើចត្តាឡីស័ក

បន្ទាប់ពីទទួលបានការត្រួតពិនិត្យឯកសារតម្រូវដូចខាងលើ អ្នកដំណើរនឹងត្រូវបានពិនិត្យសុខភាពនិងយកសំណាកដើម្បីធ្វើតេស្ត PCR ដោយមន្ត្រីសុខាភិបាល នៅទីតាំងពិសេសក្នុងស្ថានីយមកដល់របស់អ្នកដំណើរតែម្តង មុននឹងទៅធ្វើចត្តាឡីស័កចំនួន ៣ថ្ងៃពេញលេញ និងស្ថិតក្រោមការត្រួតពិនិត្យរបស់ស្ថានទូត អង្គការអន្តរជាតិសាមី និងមន្ត្រីសុខាភិបាល នៅនិវេសនដ្ឋានរបស់ស្ថានទូតឬគេហដ្ឋានដាច់ដោយឡែក ដូចមានបញ្ជាក់ក្នុងលិខិតលេខ៣៨៣ សខល ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១ របស់ក្រសួងសុខាភិបាល ឬសណ្ឋាគារដែលបានកក់ ដោយចំណាយទាំងអស់ជាបន្ទុករបស់សាមីខ្លួនផ្ទាល់ ឬស្ថានទូត ឬអង្គការអន្តរជាតិផ្ទាល់។

ការធ្វើដំណើរចេញពីច្រកទ្វារចេញ-ចូលប្រទេស ឆ្ពោះទៅកាន់និវេសនដ្ឋានរបស់ស្ថានទូតឬគេហដ្ឋានដាច់ដោយឡែក ត្រូវប្រើប្រាស់តែមធ្យោបាយដឹកជញ្ជូនរបស់ស្ថានទូតឬអង្គការអន្តរជាតិ។ ចំពោះការធ្វើដំណើរទៅសណ្ឋាគារដូចបានរៀបរាប់ខាងលើ ត្រូវប្រើប្រាស់តែមធ្យោបាយដឹកជញ្ជូនរបស់សណ្ឋាគារ ដែលបានកក់ហើយតែប៉ុណ្ណោះ។

ក្នុងករណីមានការរកឃើញវីរុសកូវីដ-១៩ វិជ្ជមាន បញ្ជាក់ដោយមន្ទីរពិសោធន៍ អ្នកជំងឺអាចបញ្ជូនទៅកាន់ទីតាំងព្យាបាលនៅនិវេសនដ្ឋានរបស់ស្ថានទូតឬទីតាំងដាច់ដោយឡែកដែលមានលក្ខខណ្ឌសមស្រប ដែលស្ថានទូតឬអង្គការអន្តរជាតិសំណូមពរ ឬទៅទីតាំងព្យាបាលដែលទទួលស្គាល់និងអនុញ្ញាតដោយក្រសួងសុខាភិបាល ដើម្បីធ្វើការព្យាបាល។ រាល់ការចំណាយ ជាបន្ទុករបស់មន្ត្រីការទូតបរទេសដែលកាន់ទិដ្ឋាការការទូត (Visa A) និងទិដ្ឋាការផ្លូវការ (Visa B) និងមន្ត្រីអនុវត្តគម្រោងសហប្រតិបត្តិការផ្លូវការ និងក្រុមគ្រួសារផ្ទាល់ ឬស្ថានទូត ឬអង្គការអន្តរជាតិផ្ទាល់។

ក្នុងករណីធ្វើចត្តាឡីស័កនៅស្ថានទូត និវេសនដ្ឋាន ឬទីតាំងដាច់ដោយឡែកដែលមានលក្ខខណ្ឌសមស្រប ត្រូវជូនដំណឹងទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងចម្លងជូនក្រសួងសុខាភិបាល និងគប្បីអនុវត្តតាមនីតិវិធីសម្រាប់ការធ្វើចត្តាឡីស័កនៅតាមផ្ទះ ហើយក្នុងករណីធ្វើចត្តាឡីស័កនៅសណ្ឋាគារគប្បីអនុវត្តតាមនទីតិវិធីប្រតិបត្តិស្តង់ដាសម្រាប់ការគ្រប់គ្រងអ្នកដំណើរនៅតាមសណ្ឋាគារចត្តាឡីស័ក ជាធរមាន។

**៤-អ្នកដំណើរបរទេសដែលជាវិនិយោគិន បុគ្គលិកជំនាញបច្ចេកទេស បុគ្គលិកក្រុមហ៊ុន និងក្រុមគ្រួសារដែលមានការធានា ឬការអញ្ជើញ**

អ្នកដំណើរបរទេសអាចជា **វិនិយោគិន បុគ្គលិកជំនាញបច្ចេកទេស បុគ្គលិកក្រុមហ៊ុន និងក្រុមគ្រួសារ**។ ដើម្បីទទួលបានទិដ្ឋាការចូលមកកម្ពុជាអ្នកទាំងនោះត្រូវមានការធានា ឬការអញ្ជើញពីដៃគូក្នុងស្រុក ដែលជានីតិបុគ្គលស្របច្បាប់ មានការចុះបញ្ជី និងបង់ពន្ធត្រឹមត្រូវនៅកម្ពុជា។ យន្តការនៃការធានានិងការអញ្ជើញនេះត្រូវធ្វើលើថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) តាមរយៈគេហទំព័រ www.registrationservices.gov.kh ដោយភ្ជាប់នូវព័ត៌មានដូចខាងក្រោម÷

- ព័ត៌មានរបស់ក្រុមហ៊ុន ជាអាទិ៍ ឈ្មោះក្រុមហ៊ុន លេខវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម លេខគម្រោងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ឬលេខអត្តសញ្ញាណកម្មសារពើពន្ធ លេខទំនាក់ទំនង អាសយដ្ឋាន អ៊ីម៉ែល
- ព័ត៌មានរបស់អ្នកធានា ឬអ្នកអញ្ជើញ ជាអាទិ៍ ឈ្មោះ ថ្ងៃខែឆ្នាំកំណើត លេខទំនាក់ទំនង លេខលិខិតឆ្លងដែន ឬលេខអត្តសញ្ញាណប័ណ្ណ
- ព័ត៌មានរបស់អ្នកដំណើរ ជាអាទិ៍ ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត ទំនាក់ទំនងជាមួយអ្នកធានា លេខទំនាក់ទំនង លេខលិខិតឆ្លងដែន លេខបណ្ណការងារ (បើមាន) សញ្ជាតិ រយៈពេលស្នាក់នៅកម្ពុជា វត្ថុបំណងនៃការធ្វើដំណើរមកកាន់ប្រទេសកម្ពុជា និងព័ត៌មាននៃការចាក់វ៉ាក់សាំង។ ក្នុងករណីមានបណ្ណការងារ អ្នកស្នើសុំអាចបំពេញលេខសម្គាល់បណ្ណការងារ និងថ្ងៃខែឆ្នាំកំណើតរបស់អ្នកដំណើរ នោះព័ត៌មានរបស់អ្នកដំណើរនោះនឹងបំពេញដោយស្វ័យប្រវត្តិលើពាក្យស្នើសុំ តាមរយៈការផ្លាស់ប្តូរទិន្នន័យលើថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX)។

ក្នុងរយៈពេលយ៉ាងយូរ**៣(បី)ថ្ងៃនៃថ្ងៃធ្វើការ** អ្នកស្នើសុំនឹងទទួលបាននូវការឆ្លើយតបដូចខាងក្រោម÷

- ក្នុងករណីមិនឯកភាព អ្នកស្នើសុំនឹងទទួលបាននូវមូលហេតុជាក់លាក់មួយ ដែលអាចធ្វើការកែតម្រូវ និងធ្វើការស្នើសុំម្តងទៀត
- ក្នុងករណីឯកភាព អ្នកស្នើសុំនឹងទទួលបានលិខិតបញ្ជាក់លើការធានា ឬលិខិតបញ្ជាក់លើការអញ្ជើញតាមការស្នើសុំ។

**លិខិតបញ្ជាក់លើការធានា**÷ ជាលិខិតដែលបញ្ជាក់ថា អ្នកស្នើសុំដែលជាអ្នកធានា គឺជាអ្នកទទួលខុសត្រូវទាំងស្រុងលើចំណាយទាំងអស់ពាក់ព័ន្ធនឹងការធ្វើចត្តាឡីស័កនិង/ឬការព្យាបាល ក្នុងករណីដែលអ្នកដំណើរមានការឆ្លងជំងឺកូវីដ-១៩ ក្នុងអំឡុងពេលធ្វើចត្តាឡីស័កនិងស្នាក់នៅកម្ពុជា។

**លិខិតបញ្ជាក់លើការអញ្ជើញ**÷ ជាលិខិតដែលបញ្ជាក់ថា អ្នកដំណើរគឺជាអ្នកទទួលខុសត្រូវទាំងស្រុងលើចំណាយទាំងអស់ដោយខ្លួនឯង។ លិខិតបញ្ជាក់ទាំងពីរប្រភេទខាងលើ ដូចមានបង្ហាញគំរូក្នុងឧបសម្ព័ន្ធទី២ និងទី៣ មានសុពលភាព ៣០ថ្ងៃ ដែលអាចប្រើប្រាស់បានតែ ១ដងគត់ និងមានទម្រង់ឌីជីថល ដែលអ្នកដំណើរអាចទាញយក និងបោះពុម្ពបានដោយខ្លួនឯង តាមគេហទំព័រខាងលើ។

**៤.១- លក្ខខណ្ឌធ្វើដំណើរ**

**មុនពេលធ្វើដំណើរមកកម្ពុជា** អ្នកដំណើរបរទេសត្រូវត្រៀមរៀបចំឱ្យរួចរាល់ ដើម្បីបំពេញលក្ខខណ្ឌតម្រូវសំខាន់ៗ ដូចខាងក្រោម÷

- ត្រូវអនុវត្តវិធានការចត្តាឡីស័កចំនួន ៧ថ្ងៃ
- ក្នុងករណីអ្នកដំណើរជាបុគ្គលិកក្រុមហ៊ុន អ្នកធានាឬអ្នកអញ្ជើញត្រូវមានបណ្ណការងាររបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈគេហទំព័រ https://www.fwcms.mlvt.gov.kh/ មុនការស្នើសុំលិខិតបញ្ជាក់លើការធានា ឬលិខិតបញ្ជាក់លើការអញ្ជើញ
- ក្នុងករណីត្រូវការទិដ្ឋាការដើម្បីធ្វើដំណើរមកកម្ពុជា អ្នកដំណើរត្រូវស្នើសុំទិដ្ឋាការដែលមានសុពលភាពស្របតាមនីតិវិធីនៃច្បាប់ស្តីពីអន្តោប្រវេសន៍ពីសំណាក់ស្ថានទូតកម្ពុជា ឬពីស្ថានកុងស៊ុលកម្ពុជា។ ការស្នើសុំទិដ្ឋាការត្រូវធ្វើឡើងមុនចេញដំណើរមកកម្ពុជា **ដោយរាជរដ្ឋាភិបាលកម្ពុជាមិនទាន់អនុញ្ញាតឱ្យមានទិដ្ឋាការនៅពេលមកដល់ (Visa on Arrival) នៅឡើយ**។ អ្នកដំណើរដែលកាន់លិខិតឆ្លងដែននៃប្រទេសដែលមិនតម្រូវឱ្យស្នើសុំទិដ្ឋាការ អាចធ្វើដំណើរមកកម្ពុជា ដោយមិនចាំបាច់ស្នើសុំទិដ្ឋាការទេ
- លិខិតបញ្ជាក់លើការធានាឬលិខិតបញ្ជាក់លើការអញ្ជើញ ត្រូវធ្វើឱ្យបានរួចរាល់ មុនចូលមកដល់កម្ពុជា
- វិញ្ញាបនបត្របញ្ជាក់ថាគ្មានជំងឺកូវីដ-១៩ ក្នុងរយៈពេល ៧២ម៉ោង មុនពេលមកដល់កម្ពុជាទទួលស្គាល់ដោយអាជ្ញាធរសុខាភិបាលនៃប្រទេសសាមីឬទីសំណាក់ចុងក្រោយមុនចាកចេញមកកាន់កម្ពុជា
- បណ្ណឬវិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩ ដែលបញ្ជាក់ពីការចាក់វ៉ាក់សាំង ដូសមូលដ្ឋាន បានពេញលេញ ប្រភេទវ៉ាក់សាំង និងកាលបរិច្ឆេទនៃការចាក់វ៉ាក់សាំង
- ឯកសារកក់សណ្ឋាគារសម្រាប់ការធ្វើចត្តាឡីស័ក នៅសណ្ឋាគារណាមួយ (ដូចមានបង្ហាញក្នុងឧបសម្ព័ន្ធទី ១)។ ក្នុងករណីពុំមាន ត្រូវត្រៀមសាច់ប្រាក់ចំនួន ៦០០ ដុល្លារអាម៉េរិក ដើម្បីតម្កល់នៅច្រកចូលកម្ពុជា សម្រាប់ធានាចំណាយទាំងអស់ពាក់ព័ន្ធនឹងការធ្វើចត្តាឡីស័ក ក្នុងអំឡុងពេលធ្វើចត្តាឡីស័កនៅពេលមកដល់កម្ពុជា

- បណ្ណសន្យារ៉ាប់រងសុខភាពសម្រាប់ព្យាបាលជំងឺកូវីដ-១៩ (Covid-19 Health Insurance Policy) ដែលជាការធានារ៉ាប់រងរួមគ្នា (Insurance consortium) ដោយក្រុមហ៊ុនធានារ៉ាប់រងមួយចំនួននៅកម្ពុជា÷ ត្រូវទិញធានារ៉ាប់រងសុខភាពសម្រាប់ព្យាបាលជំងឺកូវីដ-១៩ ពីក្រុមហ៊ុនធានារ៉ាប់រងហ្វតេ ដែលជាក្រុមហ៊ុនតំណាងឱ្យការធានារ៉ាប់រងរួមគ្នា តាមរយៈគេហទំព័រ https://www.forteinsurance.com/covid-19-insurance/។
- ពេលមកដល់ច្រកទ្វារចេញ-ចូលប្រទេសកម្ពុជា អ្នកដំណើរបរទេសត្រូវបង្ហាញគ្រប់ឯកសារដែលរៀបរាប់ខាងលើ។ អាជ្ញាធរមានសមត្ថកិច្ចនឹងស្កេន QR Code លើលិខិតបញ្ជាក់លើការធានា ឬលិខិតបញ្ជាក់លើការអញ្ជើញរបស់អ្នកដំណើរ ដើម្បីធានាភាពពិតប្រាកដនៃឯកសារនេះ។

**ពេលមកដល់ច្រកទ្វារចេញ-ចូលប្រទេសកម្ពុជា** អ្នកដំណើរបរទេសត្រូវបង្ហាញគ្រប់ឯកសារ ដែលរៀបរាប់ខាងលើ។

### ៤.២- ការអនុវត្តវិធានការសុខាភិបាលនិងការធ្វើចត្តាឡីស័ក

បន្ទាប់ពីបានបំពេញគ្រប់លក្ខខណ្ឌក្នុងចំណុច៤.១ខាងលើ អ្នកដំណើរនឹងត្រូវបានពិនិត្យសុខភាព និងយកសំណាកដើម្បីធ្វើតេស្ត PCR ដោយមន្ត្រីសុខាភិបាល មុននឹងត្រូវបញ្ជូនទៅសណ្ឋាគារ ឬទីតាំងដែលកំណត់ដោយក្រសួងសុខាភិបាល ដើម្បីធ្វើចត្តាឡីស័ក។ ក្រោយពេលទៅដល់ទីតាំងចត្តាឡីស័កនៅសណ្ឋាគារ ឬទីតាំងដែលកំណត់ដោយក្រសួងសុខាភិបាល អ្នកដំណើរនឹងត្រូវរង់ចាំលទ្ធផលតេស្ត÷

- ក្នុងករណីលទ្ធផលតេស្ត PCR បញ្ជាក់ថា វិជ្ជមានកូវីដ-១៩ អ្នកដំណើរនឹងត្រូវបញ្ជូនទៅព្យាបាលនៅតាមទីតាំងព្យាបាលជំងឺកូវីដ-១៩ ដែលអនុញ្ញាតដោយក្រសួងសុខាភិបាល
- ក្នុងករណីលទ្ធផលតេស្ត PCR បញ្ជាក់ថា អវិជ្ជមានកូវីដ-១៩ អ្នកដំណើរនឹងត្រូវបញ្ចប់ការធ្វើចត្តាឡីស័ក **នៅថ្ងៃទី៣**។

ក្នុងករណីចាំបាច់ដែលអ្នកដំណើរខាងលើមិនអាចធ្វើចត្តាឡីស័កពេញលេញ អ្នកធានាឬអ្នកអញ្ជើញត្រូវដាក់លិខិតស្នើសុំទៅអនុគណៈកម្មការទី២ ជាមុន ដើម្បីស្នើសុំគោលការណ៍ពិសេសសម្រាប់ការធ្វើចត្តាឡីស័ករយៈពេលខ្លី ដោយត្រូវបង្ហាញពីហេតុផល និងភាពចាំបាច់នៃការធ្វើចត្តាឡីស័ករយៈពេលខ្លី រួមទាំងកម្មវិធីលម្អិតនៃការធ្វើដំណើរមកកម្ពុជា។ ក្រោយពីពិនិត្យលើការស្នើសុំ អនុគណៈកម្មការទី២អាចបដិសេធដោយភ្ជាប់នូវហេតុផល ឬអនុញ្ញាតដោយភ្ជាប់នូវលក្ខខណ្ឌនិងវិធានសុខាភិបាលពិសេស សម្រាប់អ្នកដំណើរនិងអ្នកធានាយកទៅអនុវត្តដោយការទទួលខុសត្រូវខ្ពស់ចំពោះមុខច្បាប់នៃព្រះរាជាណាចក្រកម្ពុជាជាធរមាន។

## ៥- អ្នកដំណើរទូទៅជាជនជាតិខ្មែរ ឬជនបរទេស

### ៥.១- សម្រាប់ជនជាតិខ្មែរ

អ្នកដំណើរទូទៅសំដៅដល់ជនជាតិខ្មែរដែលកាន់លិខិតឆ្លងដែនខ្មែរ ឬកាន់លិខិតឆ្លងដែនបរទេស ប៉ុន្តែមានទិដ្ឋាការប្រភេទ K។

### ៥.១.១- លក្ខខណ្ឌធ្វើដំណើរ

**មុនពេលធ្វើដំណើរមកដល់កម្ពុជា** អ្នកដំណើរត្រូវត្រៀមឱ្យរួចរាល់នូវឯកសារ ដូចខាងក្រោម÷

- វិញ្ញាបនបត្របញ្ជាក់ថាគ្មានជំងឺកូវីដ-១៩ ក្នុងរយៈពេល ៧២ម៉ោង មុនពេលមកដល់កម្ពុជា ទទួលស្គាល់ដោយអាជ្ញាធរសុខាភិបាលនៃប្រទេសសាមីឬទីសំណាក់ចុងក្រោយមុនចាកចេញមកកាន់កម្ពុជា
- ត្រូវមានបណ្ណឬវិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩ ដែលបញ្ជាក់ពីការចាក់វ៉ាក់សាំង ដូសមូលដ្ឋានបានពេញលេញ ប្រភេទវ៉ាក់សាំង និងកាលបរិច្ឆេទនៃការចាក់វ៉ាក់សាំង
- ទិដ្ឋាការប្រភេទ K ក្នុងករណីអ្នកដំណើរជាជនជាតិខ្មែរកាន់លិខិតឆ្លងដែនបរទេស។ ការស្នើសុំទិដ្ឋាការត្រូវធ្វើឡើងមុនចេញដំណើរមកកម្ពុជា **ដោយរាជរដ្ឋាភិបាលកម្ពុជាមិនទាន់អនុញ្ញាតឱ្យមានទិដ្ឋាការនៅពេលមកដល់ (Visa on Arrival) នៅឡើយ**។ អ្នកដំណើរដែលកាន់លិខិតឆ្លងដែននៃប្រទេសដែលមិនតម្រូវឱ្យស្នើសុំទិដ្ឋាការ អាចធ្វើដំណើរមកកម្ពុជា ដោយមិនចាំបាច់ស្នើសុំទិដ្ឋាការទេ
- ឯកសារបញ្ជាក់ការកក់សណ្ឋាគារ ក្នុងករណីអ្នកដំណើរចង់ធ្វើចត្តាឡីស័កនៅសណ្ឋាគារ ដែលទទួលសេវាកក់តាមអនឡាញ (ដូចមានបង្ហាញក្នុងឧបសម្ព័ន្ធទី១)។

**ពេលមកដល់ច្រកទ្វារចេញ-ចូលប្រទេសកម្ពុជា** អ្នកដំណើរត្រូវបង្ហាញគ្រប់ឯកសារពាក់ព័ន្ធខាងលើ។

### ៥.១.២- ការអនុវត្តវិធានការសុខាភិបាលនិងការធ្វើចត្តាឡីស័ក

បន្ទាប់ពីទទួលបានការត្រួតពិនិត្យឯកសារតម្រូវដូចខាងលើ អ្នកដំណើរនឹងត្រូវបានពិនិត្យសុខភាព និងយកសំណាកដោយមន្ត្រីសុខាភិបាល មុនទៅសណ្ឋាគារ ឬទីតាំងដែលកំណត់ដោយក្រសួងសុខាភិបាល ដើម្បីធ្វើចត្តាឡីស័ក ក្នុងរយៈពេល **៧ថ្ងៃ**÷

- ក្នុងករណីលទ្ធផលតេស្តលើកទី១ ដោយប្រើ Rapid Test (នៅពេលមកដល់កម្ពុជា) វិជ្ជមានកូវីដ-១៩ អ្នកដំណើរនឹងត្រូវដាក់ឱ្យរង់ចាំនៅកន្លែងដាច់ដោយឡែក (Isolation Area) ដែលកំណត់ដោយក្រសួងសុខាភិបាល និងរង់ចាំលទ្ធផល PCR។ នៅពេលបានទទួលលទ្ធផលវិជ្ជមានកូវីដ-១៩ អ្នកជំងឺអាចដាក់ឱ្យព្យាបាល ឬបញ្ជូនទៅទីកន្លែងព្យាបាល ដែលអនុញ្ញាតដោយក្រសួងសុខាភិបាល។ ក្នុងករណីអវិជ្ជមានកូវីដ-១៩ អ្នកដំណើរត្រូវបន្តធ្វើចត្តាឡីស័ករយៈពេលចំនួន ៧ថ្ងៃ ហើយអ្នកដំណើរត្រូវទទួលការយកសំណាកលើកទី២ ធ្វើតេស្ត PCR នៅថ្ងៃទី៦
- ក្នុងករណីលទ្ធផលតេស្តលើកទី១ ដោយប្រើ Rapid Test អវិជ្ជមានកូវីដ-១៩ អ្នកដំណើរត្រូវបន្តធ្វើចត្តាឡីស័ករយៈពេលចំនួន ៧ថ្ងៃ ហើយអ្នកដំណើរត្រូវទទួលការយកសំណាកលើកទី២ ធ្វើតេស្ត PCR នៅថ្ងៃទី៦។ ក្នុងករណីលទ្ធផលបញ្ជាក់ថាវិជ្ជមានកូវីដ-១៩ ត្រូវបញ្ជូនទៅព្យាបាល នៅមណ្ឌលព្យាបាលឬព្យាបាល នៅតាមផ្ទះ តាមការកំណត់ដោយក្រសួងសុខាភិបាល ដោយអនុលោមតាម

នីតិវិធីប្រតិបត្តិស្តង់ដាសម្រាប់គ្រប់គ្រង ថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ។ ក្នុងករណីលទ្ធផលបញ្ជាក់ថា អវិជ្ជមានកូវីដ-១៩ ត្រូវបញ្ចប់ការធ្វើចត្តាឡីស័ក។

ក្នុងករណីអ្នកដំណើរមានបំណងប្រើប្រាស់សេវាចត្តាឡីស័កនៅសណ្ឋាគារបង់ថ្លៃសេវាដោយខ្លួនឯង មន្ត្រីសម្របសម្រួលនៅច្រកចេញ-ចូលប្រទេសរៀបចំឱ្យអ្នកដំណើរបានទៅធ្វើចត្តាឡីស័កនៅសណ្ឋាគារ បន្ទាប់ពីបានយកសំណាករួចរាល់។

ក្នុងករណីអ្នកដំណើរសុខចិត្តស្នាក់នៅសណ្ឋាគារដែលកំណត់ដោយក្រសួងសុខាភិបាល ការចំណាយជាបន្ទុករបស់រដ្ឋ។

ក្នុងករណីគេហដ្ឋានរបស់អ្នកដំណើរជាជនជាតិខ្មែរខាងលើ មានភាពសមស្របដល់ការធ្វើចត្តាឡីស័កស្របតាមវិធានការចត្តាឡីស័កនៅផ្ទះ អ្នកដំណើរអាចស្នើសុំមកអនុគណៈកម្មការទី២ យ៉ាងតិច ៣ថ្ងៃនៃថ្ងៃធ្វើការមុនពេលមកដល់កម្ពុជា ដើម្បីធ្វើចត្តាឡីស័កនៅផ្ទះ។ ក្រោយពីពិនិត្យលើការស្នើសុំ អនុគណៈកម្មការទី២ អាចបដិសេធឬឯកភាពអនុញ្ញាតដោយភ្ជាប់នូវលក្ខខណ្ឌ និងវិធានសុខាភិបាលសម្រាប់អ្នកដំណើរអនុវត្តដោយការទទួលខុសត្រូវខ្ពស់ចំពោះមុខច្បាប់នៃព្រះរាជាណាចក្រកម្ពុជាជាធរមាន។

**កំណត់សម្គាល់÷** អ្នកដំណើរជនជាតិខ្មែរ ដែលជា **វិនិយោគិន បុគ្គលិកជំនាញបច្ចេកទេស និងក្រុមគ្រួសារ** និងមានការធានា ឬការអញ្ជើញពីដៃគូក្នុងស្រុក ដែលជានីតិបុគ្គលស្របច្បាប់ មានការចុះបញ្ជី និងបង់ពន្ធត្រឹមត្រូវនៅកម្ពុជា ក៏អាចធ្វើការស្នើលិខិតបញ្ជាក់លើការធានា ឬការអញ្ជើញ តាមយន្តការ ដែលបានរៀបរាប់នៅចំណុចទី៤ ខាងលើដែរ ដើម្បីទទួលបានការធ្វើចត្តាឡីស័កចំនួន **៣ថ្ងៃ**។

### ៥.២-អ្នកដំណើរទូទៅជាជនបរទេស

អ្នកដំណើរទូទៅជាជនបរទេស សំដៅដល់អ្នកដំណើរបរទេសទូទៅ ដោយរាប់បញ្ចូលទាំងអ្នកទេសចរ និងវិនិយោគិន បុគ្គលិកជំនាញបច្ចេកទេស និងក្រុមគ្រួសារ ដែលមិនមានការធានា ឬការអញ្ជើញ។

### ៥.២.១-លក្ខខណ្ឌធ្វើដំណើរ

**មុនពេលធ្វើដំណើរមកកម្ពុជា** អ្នកដំណើរបរទេសត្រូវត្រៀមរៀបចំឱ្យរួចរាល់ ដើម្បីបំពេញលក្ខខណ្ឌតម្រូវសំខាន់ៗ ដូចខាងក្រោម÷

- វិញ្ញាបនបត្របញ្ជាក់ថាគ្មានជំងឺកូវីដ-១៩ ក្នុងរយៈពេល ៧២ម៉ោង មុនពេលមកដល់កម្ពុជា ទទួលស្គាល់ដោយអាជ្ញាធរសុខាភិបាលនៃប្រទេសសាមីឬទីសំណាក់ចុងក្រោយមុនចាកចេញមកកាន់កម្ពុជា
- ត្រូវមានបណ្ណឬវិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩ ដែលបញ្ជាក់ពីការចាក់វ៉ាក់សាំង ដូសមូលដ្ឋានបានពេញលេញ ប្រភេទវ៉ាក់សាំង និងកាលបរិច្ឆេទនៃការចាក់វ៉ាក់សាំង
- ក្នុងករណីត្រូវការទិដ្ឋាការដើម្បីធ្វើដំណើរមកកម្ពុជា អ្នកដំណើរត្រូវស្នើសុំទិដ្ឋាការដែលមានសុពលភាពស្របតាមនីតិវិធីនៃច្បាប់ស្តីពីអន្តោប្រវេសន៍ ពីសំណាក់ស្ថានទូតកម្ពុជា ឬពីស្ថានកុងស៊ុលកម្ពុជា ។ ការស្នើសុំទិដ្ឋាការត្រូវធ្វើឡើងមុនចេញដំណើរមកកម្ពុជា **ដោយរាជរដ្ឋាភិបាលកម្ពុជាមិនទាន់**

**អនុញ្ញាតឱ្យមានទិដ្ឋាការនៅពេលមកដល់ (Visa on Arrival) នៅឡើយ**។ អ្នកដំណើរដែលកាន់លិខិតឆ្លងដែននៃប្រទេសដែលមិនតម្រូវឱ្យស្នើសុំទិដ្ឋាការ អាចធ្វើដំណើរមកកម្ពុជា ដោយមិនចាំបាច់ស្នើសុំទិដ្ឋាការទេ

- ក្នុងករណីអ្នកដំណើរបរទេសជាបុគ្គលិក ដែលត្រូវបម្រើការងារនៅក្រុមហ៊ុនមានមូលដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា ហើយបណ្ណការងារអស់សុពលភាពឬមិនទាន់មាន អ្នកដំណើរបរទេសត្រូវធ្វើការស្នើសុំបណ្ណការងាររបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈគេហទំព័រ https://www.fwcms.mlvt.gov.kh/
- ឯកសារកក់សណ្ឋាគារសម្រាប់ការធ្វើចត្តាឡីស័ក នៅសណ្ឋាគារណាមួយ (ដូចមានបង្ហាញក្នុងឧបសម្ព័ន្ធទី ១)។ ក្នុងករណីពុំមាន ត្រូវត្រៀមសាច់ប្រាក់ចំនួន ១ ០០០ ដុល្លារអាម៉េរិក ដើម្បីតម្កល់នៅច្រកចូលកម្ពុជា សម្រាប់ធានាចំណាយទាំងអស់ពាក់ព័ន្ធនឹងការធ្វើចត្តាឡីស័ក ក្នុងអំឡុងពេលធ្វើចត្តាឡីស័កនៅពេលមកដល់កម្ពុជា
- បណ្ណសន្យារ៉ាប់រងសុខភាពសម្រាប់ព្យាបាលជំងឺកូវីដ-១៩ (Covid-19 Health Insurance Policy) ដែលជាការធានារ៉ាប់រងរួមគ្នា (Insurance consortium) ដោយក្រុមហ៊ុនធានារ៉ាប់រងមួយចំនួននៅកម្ពុជា÷ ត្រូវទិញធានារ៉ាប់រងសុខភាពសម្រាប់ព្យាបាលជំងឺកូវីដ-១៩ ពីក្រុមហ៊ុនធានារ៉ាប់រងហ្វតេ ដែលជាក្រុមហ៊ុនតំណាងឱ្យការធានារ៉ាប់រងរួមគ្នា តាមរយៈគេហទំព័រ https://www.forteinsurance.com/covid-19-insurance/ ។

**ពេលមកដល់ច្រកទ្វារចេញ-ចូលប្រទេសកម្ពុជា** អ្នកដំណើរបរទេសត្រូវបង្ហាញគ្រប់ឯកសារ ដែលរៀបរាប់ខាងលើ។

## ៥.២.២-ការអនុវត្តវិធានការសុខាភិបាលនិងការធ្វើចត្តាឡីស័ក

បន្ទាប់ពីទទួលបានការត្រួតពិនិត្យឯកសារតម្រូវដូចខាងលើ អ្នកដំណើរបរទេសនឹងត្រូវបានពិនិត្យសុខភាព និងយកសំណាកដោយមន្ត្រីសុខាភិបាល មុននឹងត្រូវបញ្ជូនទៅសណ្ឋាគារ ឬទីតាំងដែលកំណត់ដោយក្រសួងសុខាភិបាល ដើម្បីធ្វើចត្តាឡីស័ក ក្នុងរយៈពេល **៧ថ្ងៃ**÷

- ក្នុងករណីលទ្ធផលតេស្តលើកទី១ ដោយប្រើ Rapid Test (នៅពេលមកដល់កម្ពុជា) វិជ្ជមានកូវីដ-១៩ អ្នកដំណើរនឹងត្រូវដាក់ឱ្យរង់ចាំនៅកន្លែងដាច់ដោយឡែក (Isolation Area) ដែលកំណត់ដោយក្រសួងសុខាភិបាល និងរង់ចាំលទ្ធផល PCR។ នៅពេលបានទទួលលទ្ធផលវិជ្ជមានកូវីដ-១៩ អ្នកជំងឺអាចដាក់ឱ្យព្យាបាល ឬបញ្ជូនទៅទីកន្លែងព្យាបាល ដែលអនុញ្ញាតដោយក្រសួងសុខាភិបាល។ ក្នុងករណីអវិជ្ជមានកូវីដ-១៩ អ្នកដំណើរត្រូវបន្តធ្វើចត្តាឡីស័ករយៈពេលចំនួន ៧ថ្ងៃ ហើយអ្នកដំណើរត្រូវទទួលការយកសំណាកលើកទី២ ធ្វើតេស្ត PCR នៅថ្ងៃទី៦
- ក្នុងករណីលទ្ធផលតេស្តលើកទី១ ដោយប្រើ Rapid Test អវិជ្ជមានកូវីដ-១៩ អ្នកដំណើរត្រូវបន្តធ្វើចត្តាឡីស័ករយៈពេលចំនួន **៧ថ្ងៃ** ហើយអ្នកដំណើរត្រូវទទួលការយកសំណាកលើកទី២ ធ្វើតេស្ត

PCR នៅថ្ងៃទី៦នៃការធ្វើចត្តាឡីស័ក។ ក្នុងករណីលទ្ធផលបញ្ជាក់ថា វិជ្ជមានកូវីដ-១៩ ត្រូវបញ្ជូនទៅព្យាបាល នៅមណ្ឌលព្យាបាលឬព្យាបាល នៅតាមផ្ទះ តាមការកំណត់ដោយក្រសួងសុខាភិបាល ដោយអនុលោមតាមនីតិវិធីប្រតិបត្តិស្តង់ដាសម្រាប់គ្រប់គ្រង ថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ។ ក្នុងករណីលទ្ធផលបញ្ជាក់ថា អវិជ្ជមានកូវីដ-១៩ ត្រូវបញ្ចប់ការធ្វើចត្តាឡីស័ក។

## ២. អ្នកដំណើរគ្រប់ប្រភេទដែលមិនបានចាក់វ៉ាក់សាំងកូវីដ-១៩ ឬមិនទាន់ចាក់វ៉ាក់សាំងដូសមូលដ្ឋាន បានពេញលេញ

ចំពោះក្រុមអ្នកដំណើរដែលបានរៀបរាប់ខាងលើ ករណីមិនទាន់បានចាក់វ៉ាក់កូវីដ-១៩ ឬចាក់វ៉ាក់សាំងមិនទាន់បានពេញលេញ ការអនុវត្តលក្ខខណ្ឌធ្វើដំណើរ ត្រូវអនុវត្តដូចបានរៀបរាប់ខាងលើ(ចំណុចទី១ ទី២ ទី៣ ទី៤ និងទី៥) ប៉ុន្តែរយៈពេលត្រូវធ្វើចត្តាឡីស័កមានរហូតដល់ **១៤ថ្ងៃ** ដោយត្រូវអនុវត្តវិធានការសុខាភិបាល និងត្រូវមានឯកសារកក់សណ្ឋាគារសម្រាប់ការធ្វើចត្តាឡីស័ក នៅសណ្ឋាគារណាមួយ(ដូចមានបង្ហាញក្នុងឧបសម្ព័ន្ធទី១)។ ក្នុងករណីពុំមាន ត្រូវត្រៀមសាច់ប្រាក់ចំនួន ២ ០០០(ពីរពាន់) ដុល្លារអាមេរិក(សម្រាប់អ្នកដំណើរបរទេស) ដើម្បីតម្កល់នៅច្រកចូលកម្ពុជា សម្រាប់ធានាចំណាយទាំងអស់ពាក់ព័ន្ធនឹងការធ្វើចត្តាឡីស័ក ក្នុងអំឡុងពេលធ្វើចត្តាឡីស័កនៅពេលមកដល់កម្ពុជា។

អ្នកដំណើរនឹងត្រូវបានពិនិត្យសុខភាព និងយកសំណាកដោយមន្ត្រីសុខាភិបាល មុននឹងត្រូវបញ្ជូនទៅសណ្ឋាគារ ឬទីតាំងដែលកំណត់ដោយក្រសួងសុខាភិបាល ដើម្បីធ្វើចត្តាឡីស័ក ÷

- ក្នុងករណីលទ្ធផលតេស្តលើកទី១ ដោយប្រើ Rapid Test (នៅពេលមកដល់កម្ពុជា) វិជ្ជមានកូវីដ-១៩ អ្នកដំណើរនឹងត្រូវដាក់ឱ្យរង់ចាំនៅកន្លែងដាច់ដោយឡែក (Isolation Area) ដែលកំណត់ដោយក្រសួងសុខាភិបាល និងរង់ចាំលទ្ធផល PCR។ នៅពេលបានទទួលលទ្ធផលវិជ្ជមានកូវីដ-១៩ អ្នកជំងឺអាចដាក់ឱ្យព្យាបាល ឬបញ្ជូនទៅទីកន្លែងព្យាបាល ដែលអនុញ្ញាតដោយក្រសួងសុខាភិបាល។ ក្នុងករណីអវិជ្ជមានកូវីដ-១៩ អ្នកដំណើរត្រូវបន្តធ្វើចត្តាឡីស័ករយៈពេលចំនួន ១៤ថ្ងៃ ហើយអ្នកដំណើរត្រូវទទួលការយកសំណាកលើកទី២ ធ្វើតេស្ត PCR នៅថ្ងៃទី១៣
- ក្នុងករណីលទ្ធផលតេស្តលើកទី១ ដោយប្រើ Rapid Test អវិជ្ជមានកូវីដ-១៩ អ្នកដំណើរត្រូវបន្តធ្វើចត្តាឡីស័ករយៈពេលចំនួន ១៤ថ្ងៃ ហើយអ្នកដំណើរត្រូវទទួលការយកសំណាកលើកទី២ ដោយធ្វើតេស្ត PCR នៅថ្ងៃទី១៣នៃការធ្វើចត្តាឡីស័ក។ ក្នុងករណីលទ្ធផលបញ្ជាក់ថា វិជ្ជមានកូវីដ-១៩ ត្រូវបញ្ជូនទៅព្យាបាល។ ក្នុងករណីលទ្ធផលបញ្ជាក់ថា អវិជ្ជមានកូវីដ-១៩ ត្រូវបញ្ចប់ការធ្វើចត្តាឡីស័ក នៅថ្ងៃទី១៤។

ក្នុងករណីសមាជិកគ្រួសារដែលមិនបានចាក់វ៉ាក់សាំងហើយមានអាយុក្រោម១៨ឆ្នាំ ដែលរួមដំណើរចូលមកកម្ពុជាជាមួយអ្នកដំណើរដូចបានរៀបរាប់ខាងលើ (ចំណុចទី២ ទី៣ ទី៤ និងទី៥) រយៈពេលធ្វើចត្តាឡីស័កត្រូវអនុវត្តដូចគ្នានឹងរយៈពេលធ្វើចត្តាឡីស័ករបស់អ្នកដំណើរដែលជាអាណាព្យាបាល។

# តារាងសង្ខេបស្តីពីការធ្វើចត្តាឡីស័កសម្រាប់អ្នកដំណើរមកកម្ពុជាតាមគ្រប់ច្រកចូល

| ល.រ | បរិយាយ | ចំនួនថ្ងៃចត្តាឡីស័ក | ធ្វើតេស្ត |
|---|---|---|---|
| **អ្នកដំណើរដែលទទួលបានការចាក់វ៉ាក់សាំងដូសមូលដ្ឋានបានពេញលេញ** | | | |
| ១ | ភ្ញៀវផ្លូវការរបស់រាជរដ្ឋាភិបាលនិងមន្ត្រីថ្នាក់ដឹកនាំជាន់ខ្ពស់របស់រាជរដ្ឋាភិបាលដែលត្រឡប់ពីបំពេញបេសកកម្មនៅក្រៅប្រទេស | អនុវត្តរបបពិសេសទៅតាមការសម្រេចរបស់រាជរដ្ឋាភិបាល | |
| ២ | វិនិយោគិន បុគ្គលិកជំនាញបច្ចេកទេស បុគ្គលិកក្រុមហ៊ុន ទាំងជនជាតិខ្មែរនិងបរទេស មន្ត្រីការទូត មន្ត្រីអនុវត្តគម្រោងសហប្រតិបត្តិការផ្លូវការ និងមន្ត្រីរាជការរបស់រាជរដ្ឋាភិបាល ដែលត្រឡប់ពីបំពេញបេសកកម្មនៅក្រៅប្រទេស (ដោយរួមបញ្ចូលក្រុមគ្រួសាររបស់ក្រុមអាទិភាពនេះ) | **៣ថ្ងៃ** | PCR តែម្តងគត់ នៅច្រកចេញ-ចូលប្រទេស |
| ៣ | អ្នកដំណើរទូទៅដែលជាជនជាតិខ្មែរឬជនបរទេស | **៧ថ្ងៃ** | **លើកទី១**÷ RDT នៅច្រកចេញ-ចូលប្រទេស (ពេលមកដល់) **លើកទី២**÷ PCR (ថ្ងៃទី៦) |
| **អ្នកដំណើរមិនបានវ៉ាក់សាំងកូវីដ-១៩ ឬមិនទាន់ចាក់វ៉ាក់សាំងដូសមូលដ្ឋានបានពេញលេញ** | | | |
| ៤ | អ្នកដំណើរគ្រប់ប្រភេទដែលមិនបានចាក់វ៉ាក់សាំងកូវីដ-១៩ ឬមិនទាន់ចាក់វ៉ាក់សាំងដូសមូលដ្ឋានបានពេញលេញ។ | **១៤ថ្ងៃ** | **លើកទី១**÷ RDT (នៅច្រកចេញ-ចូលប្រទេស (ពេលមកដល់) **លើកទី២**÷ PCR (ថ្ងៃទី១៣) |

## ឧបសម្ព័ន្ធទី១

## បញ្ជីសណ្ឋាគារដែលទទួលកក់សេវាធ្វើចត្តាឡីស័ក

| ល.រ. | ឈ្មោះសណ្ឋាគារ | គេហទំព័រ |
|---|---|---|
| ១ | Sokha Phnom Penh Residence | https://sokhahotels.com.kh/phnompenh/ |
| ២ | Courtyard by Marriott | https://www.marriott.com/hotels/travel/pnhcy-courtyard-phnom-penh/ |
| ៣ | Raffles Hotel Le Royal | https://www.raffles.com/phnom-penh/ |
| ៤ | Sofitel Phnom Penh Phokeethra | https://www.sofitel-phnompenh-phokeethra.com/ |
| ៥ | Himawari | http://www.himawarihotel.com/ |

# ឧបសម្ព័ន្ធទី២

# គំរូលិខិតបញ្ជាក់លើការធានា

# សម្រាប់អ្នកចាក់វ៉ាក់សាំងដូសមូលដ្ឋានបានពេញលេញ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតបញ្ជាក់លើការធានា

VALIDATION CERTIFICATE ON GUARANTEE

លេខវិញ្ញាបនបត្រ(No.):**000000012**

**រាជរដ្ឋាភិបាលកម្ពុជា**

សូមបញ្ជាក់ថាក្រុមហ៊ុនឈ្មោះ **MY KHMER FARM CO., LTD.**
ដែលមានអាសយដ្ឋាន **#292, St 789, Tuol Kork, Phnom Penh**
ជាមួយនឹងលេខទូរស័ព្ទក្រុមហ៊ុន **+85592888296** បានធានាទទួលខុសត្រូវទាំងស្រុង លើចំណាយទាំងអស់ពាក់ព័ន្ធនឹងការធ្វើចត្តាឡីស័ក និង/ឬការព្យាបាល ក្នុងករណីដែលអ្នកដំណើរខាងក្រោមនេះ ត្រូវបានតម្រូវដោយស្ថាប័នមានសមត្ថកិច្ចរបស់កម្ពុជាឱ្យធ្វើចត្តាឡីស័ក និង/ឬធ្វើការព្យាបាលជំងឺកូវីដ-១៩ នៅពេលធ្វើដំណើរមកដល់កម្ពុជា។ ព័ត៌មានអ្នកដំណើរមានដូចខាងក្រោម៖

ឈ្មោះ **DARA SOK** កើតថ្ងៃទី **02 January 1990**

តួនាទី **CEO** លិខិតឆ្លងដែនលេខ **H3234324**

**The Royal Government of Cambodia**

Certifies that **MY KHMER FARM CO., LTD.** located at **#292, St 789, Tuol Kork, Phnom Penh** with company's phone number **+85592888296**, has pledged to be entirely responsible for paying all expenses related to quarantine and/or treatment, should the below traveler is required by Cambodia's authorized institutions to quarantine and/or receive Covid-19 treatment upon arrival in Cambodia. The information of the traveler is as detailed below:

Name **DARA SOK** Born on **02 January 1990**

Position **CEO** Passport No. **H3234324**

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០២១

Phnom Penh, September 27, 2021

បានចាក់វ៉ាក់សាំងពេញលេញ៖ [AstraZeneca, AB] AZD1222 Vaxzevria

Fully vaccinated: [AstraZeneca, AB] AZD1222 Vaxzevria

# ឧបសម្ព័ន្ធទី៣

# គំរូលិខិតបញ្ជាក់លើការអញ្ជើញ

# សម្រាប់អ្នកចាក់វ៉ាក់សាំងដូសមូលដ្ឋានបានពេញលេញ

សាមីខ្លួន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតបញ្ជាក់លើការអញ្ជើញ

VALIDATION CERTIFICATE ON INVITATION

លេខវិញ្ញាបនបត្រ(No.):**000000012**

**រាជរដ្ឋាភិបាលកម្ពុជា**

សូមបញ្ជាក់ថាក្រុមហ៊ុនឈ្មោះ **MY KHMER FARM CO., LTD.**
ដែលមានអាសយដ្ឋាន **#292, St 789, Tuol Kork, Phnom Penh**
ជាមួយនឹងលេខទូរស័ព្ទក្រុមហ៊ុន **+85592888296** បានអញ្ជើញអ្នកដំណើរដូចខាងក្រោម៖

ឈ្មោះ **DARA SOK** កើតថ្ងៃទី **02 January 1990**

តួនាទី **CEO** លិខិតឆ្លងដែនលេខ **H3234324**

អ្នកដំណើរខាងលើនឹងទទួលខុសត្រូវដោយខ្លួនឯងទាំងស្រុងក្នុងការចំណាយទាំងអស់ពាក់ព័ន្ធនឹងការព្យាបាល ក្នុងករណីដែលអ្នកដំណើរខាងលើនេះមានការឆ្លងជំងឺកូវីដ-១៩ និងរាល់ការចំណាយទាំងអស់ពាក់ព័ន្ធនឹងការធ្វើចត្តាឡីស័ក ក្នុងករណីដែលអ្នកដំណើរនេះត្រូវបានតម្រូវដោយស្ថាប័នមានសមត្ថកិច្ចរបស់កម្ពុជាឱ្យធ្វើចត្តាឡីស័ក។

**The Royal Government of Cambodia**

Certifies that **MY KHMER FARM CO., LTD.** located at **#292, St 789, Tuol Kork, Phnom Penh** with company's phone number **+85592888296** has invited the following traveler:

Name **DARA SOK** Born on **02 January 1990**

Position **CEO** Passport No. **H3234324**

The above traveler will entirely be responsible for paying all expense related to treatment should he/she test positive for Covid-19 and all expenses related to quarantine should he/she be required by Cambodia's authorized institution to quarantine.

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០២១

Phnom Penh, September 27, 2021

បានចាក់វ៉ាក់សាំងពេញលេញ៖ [AstraZeneca, AB] AZD1222 Vaxzevria
Fully vaccinated: [AstraZeneca, AB] AZD1222 Vaxzevria